**ខោនធី Santa Clara**

**ការិយាល័យមន្ត្រីគ្រប់គ្រងចុះឈ្មោះអ្នកបោះឆ្នោត**

1555 Berger Drive, Bldg. 2
San Jose, CA 95112
អាសយដ្ឋានសម្រាប់ផ្ញើសំបុត្រទៅ: P.O. Box 611360, San Jose, CA 95161-1360
(408) 299-VOTE (8683) (866) 430-VOTE (8683) ទូរសារ៖ (408) 998-7314
www.sccvote.org

---

ជូនចំពោះអ្នកបោះឆ្នោត

ការិយាល័យមន្ត្រីគ្រប់គ្រងចុះឈ្មោះអ្នកបោះឆ្នោត **ខោនធី Santa** Clara កំពុងតែផ្ញើលិខិត **សេចក្តីថ្លែងការណ៍ផ្ទៀងផ្ទាត់បញ្ជាក់អំពីការចុះហត្ថលេខា** នេះដោយសារតែកាចុះហត្ថលេខារបស់អ្នកនៅលើស្រោមសំបុត្រសន្លឹកឆ្នោតបណ្តោះអាសន្នរបស់អ្នកមិនត្រូវគ្នានឹងកំណត់ត្រារបស់យើងឡើយ។ ការបោះឆ្នោតរបស់អ្នកនឹងមិនត្រូវបានរាប់បញ្ចូលទេ លុះត្រាតែអ្នកធ្វើតាមជំហានដែលបានចែងនៅក្នុងលិខិតនេះ។

ដើម្បីកែកំហុសនេះ អ្នកត្រូវតែបំពេញនៅលើជម្រើសមួយ នៅក្នុងចំណោមជម្រើសដែលបានផ្តល់អោយ ហើយនិង សេចក្តីណែនាំស្តីពីថ្លែងការណ៍បញ្ជាក់ការចុះហត្ថលេខា នៅខាងខ្នងលិខិតនេះ។ ការិយាល័យមន្ត្រីគ្រប់គ្រងចុះឈ្មោះអ្នកបោះឆ្នោត ត្រូវតែអោយបាទទួលនៃសេចក្តីថ្លែងការណ៍នៅផ្នែកខាងខ្នងនៃលិខិតនេះ ឬ អ្នកអាចមកកាន់ការិយាល័យមន្ត្រីគ្រប់គ្រងចុះឈ្មោះអ្នកបោះឆ្នោត ដើម្បីចុះហត្ថលេខា ជាថ្មីឡើងវិញនៅលើស្រោមសំបុត្រសន្លឹកឆ្នោតដើមរបស់អ្នកមិនអោយក្រោយពីពេលត្រឹមម៉ោង **5:00 ល្ងាច នៅថ្ងៃ ព្រហស្បត៍ ទី 3 ខែធ្នូ ឆ្នាំ 2020** ដើម្បីធានាថាសន្លឹកឆ្នោតបណ្តោះអាសន្នរបស់អ្នកនិងត្រូវបានធ្វើដំណើរការ ហើយនិង ត្រូវបានរាប់បញ្ចូល។

<table>
<tr>
<td>ខោនធី Santa Clara<br>ការិយាល័យមន្ត្រីគ្រប់គ្រងចុះឈ្មោះអ្នកបោះឆ្នោត<br>1555 Berger Drive, Building 2<br>San Jose, CA 95112<br><br>ទូរស័ព្ទមិនគិតថ្លៃ ៖ (866) 430-VOTE (8683)<br>ទូរសារ ៖ (408) 998-7314<br>អ៊ីមែល៖ voterinfo@rov.sccgov.org</td>
<td>ម៉ោងធ្វើការ<br>ថ្ងៃចន្ទ – ថ្ងៃសុក្រ ម៉ោង 8:00 ព្រឹក – 5:00 ល្ងាច<br>(មិនរាប់បញ្ចូលថ្ងៃឈប់សម្រាក)</td>
</tr>
<tr>
<td colspan="2">សម្រាប់ទិសដៅមកកាន់ការិយាល័យរបស់យើង សូមចូលទៅ<br>www.sccgov.org/sites/rov/Resources/Pages/HoursLocationsDirections.aspx</td>
</tr>
</table>

***សេចក្តីថ្លែងការណ៍បញ្ជាក់អំពីការចុះហត្ថលេខារបស់អ្នក***
***ត្រូវតែអោយបានទទួលមកកាន់ការិយាល័យរបស់មន្ត្រីគ្រប់គ្រងចុះឈ្មោះអ្នកបោះឆ្នោត ខោនធី Santa Clara***
***មិនអោយក្រោយពីពេលត្រឹមម៉ោង 5:00 ល្ងាច នៅថ្ងៃទី 3 ខែធ្នូ ឆ្នាំ 2020 ។***

ក្រុមប្រឹក្សាភិបាលអ្នកគ្រប់គ្រង ៖ Mike Wasserman, Cindy Chavez, Dave Cortese, Susan Ellenberg, S. Joseph Simitian
មន្ត្រីប្រតិបត្តិខោនធី ៖ Jeffrey V. Smith

## សូមអានការណែនាំទាំងនេះដោយយកចិត្តទុកដាក់
## ការមិនអនុវត្តទៅតាមការណែនាំទាំងនេះនឹងអាចបណ្តាលឲ្យសន្លឹកឆ្នោតរបស់អ្នកមិនត្រូវបានរាប់បញ្ចូល

ដើម្បីឱ្យសន្លឹកឆ្នោតបណ្តោះអាសន្នរបស់អ្នកត្រូវបានរាប់បញ្ចូល សូមបំពេញនៅលើសេចក្តីថ្លែងការណ៍នៅខាងក្រោម ហើយចុះហត្ថលេខា នៅលើបន្ទាត់ខាងលើ "ហត្ថលេខារបស់អ្នកអ្នកបោះឆ្នោត" ។ អ្នកអាចផ្ញើត្រឡប់មកវិញនូវសេចក្តីថ្លែងការណ៍ដែលបានចុះហត្ថលេខារបស់អ្នកដោយប្រើជម្រើសផ្ញើត្រឡប់មកវិញណាមួយនៅខាងក្រោមនេះ៖

1. **ផ្ញើអ៊ីមែលសេចក្តីថ្លែងការណ៍ដែលបានចុះហត្ថលេខា ហើយដែលបានបំពេញរួចហើយទៅការិយាល័យរបស់យើង។** សេចក្តីថ្លែងការណ៍ដែលបានផ្ញើតាមអ៊ីមែលរួចហើយ ត្រូវតែអោយបានទទួលមកដល់ការិយាល័យរបស់យើងមិនអោយក្រោយពីត្រឹមម៉ោង 5:00 ល្ងាច *នៅថ្ងៃទី 3 ខែ ខែធ្នូ ឆ្នាំ 2020* ។ អាសយដ្ឋានអ៊ីមែលគឺ voterinfo@rov.sccgov.org ។

2. **ផ្ញើសេចក្តីថ្លែងការណ៍ដែលបានចុះហត្ថលេខាហើយដែលបានបំពេញរួចហើយទៅកាន់ការិយាល័យរបស់យើងនៅក្នុងស្រោមសំបុត្រដែលបានបិទតែមបង់ថ្លៃរួចហើយ។** សេចក្តីថ្លែងការណ៍នេះត្រូវតែអោយបានទទួលមកដល់ ការិយាល័យរបស់យើង នៅតាមអាសយដ្ឋានខាងក្រោមមិនអោយក្រោយពីត្រឹមម៉ោង 5:00 ល្ងាច *នៅថ្ងៃទី 3 ខែធ្នូ ឆ្នាំ 2020* ។ មិនអាចទទួលយកសំបុត្រដែលបានដាក់ត្រាសំគាល់តាមប្រៃសណីយ៍បានទេ។

3. **ទូរសារសេចក្តីថ្លែងការណ៍ដែលបានចុះហត្ថលេខា ហើយដែលបានបំពេញរួចហើយ ទៅកាន់ការិយាល័យរបស់យើង។** សេចក្តីថ្លែងការណ៍ដែលបានទូរសាររួចហើយ ត្រូវតែត្រូវ អោយបានទទួលមិនអោយក្រោយពី ត្រឹមម៉ោង **5:00 ល្ងាច នៅ ថ្ងៃទី 3 ខែធ្នូ ឆ្នាំ 2020** ។ លេខទូរសារគឺ 408-998-7314 ។

4. **មកកាន់ការិយាល័យមន្ត្រីគ្រប់គ្រងចុះឈ្មោះអ្នកបោះឆ្នោតដោយផ្ទាល់។** អ្នកអាចមកកាន់ការិយាល័យរបស់យើងនៅតាមអាសយដ្ឋានខាងក្រោមនេះ ចាប់ពីថ្ងៃចន្ទ រហូត ដល់ថ្ងៃ សុក្រ ពីម៉ោង 8:00 ព្រឹក ដល់ម៉ោង 5:00 ល្ងាច ដើម្បីធ្វើចុះហត្ថលេខាសាជាថ្មីឡើងវិញ នៅលើស្រោមសំបុត្រសន្លឹកឆ្នោតបណ្តោះអាសន្នដើមរបស់អ្នក ឬ ផ្ញើត្រឡប់មកវិញនូវសេចក្តីថ្លែងការណ៍ដែលមានបញ្ជាក់ការចុះហត្ថលេខារបស់អ្នក។ នេះត្រូវតែអោយបានធ្វើមិនអោយក្រោយពីពេលនៅត្រឹមម៉ោង **5:00 ល្ងាច នៅ ថ្ងៃទី 3 ខែធ្នូ ឆ្នាំ 2020** ។

### សេចក្តីថ្លែងការណ៍បញ្ជាក់អំពីការចុះហត្ថលេខា

ខ្ញុំ, ______________________________________, គឺជាអ្នកបោះឆ្នោតដែលបានចុះឈ្មោះ របស់ ខោនធី Santa Clara

(ឈ្មោះអ្នកបោះឆ្នោត)

រដ្ឋ California ។ ខ្ញុំសូមប្រកាសនៅក្រោមការពិន័យចំពោះការភូតកុហកថា ខ្ញុំពិតជាបុគ្គលដែលមានឈ្មោះនៅក្នុងស្រោមសំបុត្រសន្លឹកឆ្នោតបណ្តោះអាសន្ននេះប្រាកដមែន ។ ខ្ញុំយល់ដឹងថា ប្រសិនបើខ្ញុំប្រព្រឹត្ត ឬ ប៉ុនប៉ងក្លែងបន្លំណាមួយ ដែលពាក់ព័ន្ធនឹងការបោះឆ្នោត ឬ ប្រសិនបើខ្ញុំជួយ ឬ ការពារ នៅក្នុងការលួចបន្លំ ឬ ប៉ុនប៉ងជួយ ឬ រំលោភបំពាន នៅលើការបោះឆ្នោតនោះខ្ញុំ សូមទទួលទោសពីបទល្មើសព្រហ្មទណ្ឌដោយជាប់ពន្ធនាគាររយៈពេល 16 ខែ ឬ ពីរឆ្នាំ ឬ បីឆ្នាំ ។ ខ្ញុំយល់ថា ការខកខានក្នុងការចុះហត្ថលេខា នៅលើសេចក្តីថ្លែងការណ៍នេះ មានន័យថាសន្លឹកឆ្នោតបណ្តោះអាសន្នរបស់ខ្ញុំនឹងចាត់ទុកមិនមាន ដំណើរការសម្រាប់ក្នុងការរាប់បញ្ចូលទេ ។

(បានចុះហត្ថលេខា) ____________________________________________________________

**ហត្ថលេខារបស់អ្នកបោះឆ្នោត** (មិនអាចទទួលយកលិខិតអំណាចរបស់មេធាវីបានទេ)

(សាក្សី)____________________________________________________________

ប្រសិនបើអ្នកបោះឆ្នោតមិនអាចចុះហត្ថលេខាបានទេនោះ អ្នកបោះឆ្នោតអាចបង្កើតធ្វើជាសញ្ញាសម្គាល់ដែលត្រូវមានមនុស្សម្នាក់ធ្វើជាសាក្សី។

បានចុះថ្ងៃ ____________________ ទី ________________________________________, ឆ្នាំ 2020 ។

អាសយដ្ឋានស្នាក់នៅ ៖____________________________________________________________

អាសយដ្ឋានផ្លូវ　　　　　　ទីក្រុង　　　　　　លេខកូដតំបន់

អាសយដ្ឋានផ្ញើសំបុត្រ ៖____________________________________________________________

អាសយដ្ឋានផ្លូវ　　　　　　ទីក្រុង　　　　　　លេខកូដតំបន់

**ការិយាល័យមន្ត្រីគ្រប់គ្រងចុះឈ្មោះអ្នកបោះឆ្នោត ខោនធី Santa Clara**
**អាសយដ្ឋាន ៖** 1555 Berger Drive, Building 2, San Jose, CA 95112
**អាសយដ្ឋានផ្ញើសំបុត្រ ៖** PO Box 611360, San Jose, CA 95161-1360
**ទូរស័ព្ទឥតគិតថ្លៃ ៖** (866) 430-VOTE (8683); **ទូរសារ:** (408) 998-7314; **វិបសាយ ៖** www.sccvote.org
**ក្រុមប្រឹក្សាភិបាលអ្នកគ្រប់គ្រង ៖** Mike Wasserman, Cindy Chavez, Dave Cortese, Susan Ellenberg, S. Joseph Simitian
**មន្ត្រីប្រតិបត្តិខោនធី ៖** Jeffrey V. Smith